**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន កម្មករនិយោជិត សហជីព និងសមាគមនិយោជក ឱ្យបានជ្រាបថា យោងតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណុចជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ កម្មករនិយោជិតដែលបាននឹងកំពុងប្រើប្រាស់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (កិច្ចសន្យារយៈពេលវែង) នឹងទទួលបានការទូទាត់ប្រាក់បំណាច់អតីតភាពការងារ២ដងក្នុងមួយឆ្នាំ គឺក្នុងខែមិថុនា និងខែធ្នូ ដោយនឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីខែមិថុនា ឆ្នាំ២០១៩ តទៅ។

ចំពោះការទូទាត់បើករំលឹកប្រាក់បំណាច់អតីតភាពការងាររបស់កម្មករនិយោជិត ដែលមានមុនឆ្នាំ២០១៩ ក្រសួងកំពុងធ្វើការពិភាក្សាជាមួយវិស័យឯកជន ដើម្បីកំណត់កាលវិភាគជាក់លាក់មួយក្នុងការតម្រូវឱ្យសហគ្រាស គ្រឹះស្ថានអនុវត្តកាតព្វកិច្ចបើករំលឹកប្រាក់បំណាច់អតីតភាពការងារនេះ។

ក្នុងអំឡុងពេលនៃការទូទាត់បើករំលឹកប្រាក់បំណាច់អតីតភាពការងារនេះ ក្រសួងសូមធានាចំពោះអត្ថប្រយោជន៍ស្របច្បាប់នានាដែលបងប្អូនកម្មករនិយោជិតមាន ហើយដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬបិទទ្វារណាមួយមិនទាន់បានទូទាត់ជូនបងប្អូនកម្មករនិយោជិត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន សហជីព សមាគមនិយោជក ជាពិសេសកម្មករនិយោជិត មេត្តាជ្រាបជាព័ត៌មាននិងរក្សាភាពនឹងនរក្នុងចិត្ត ជៀសវាងចាញ់បោកជនខិលខូចមួយចំនួនដែលមានបំណងញុះញង់ បង្កអស្ថិរភាពក្នុងសហគ្រាស គ្រឹះស្ថាន ដែលអាចបំផ្លាញការងារអចិន្ត្រៃយ៍របស់បងប្អូនកម្មករនិយោជិត។

ថ្ងៃសុក្រ ៦រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩